**សម្រាប់ការចេញផ្សាយជាប្រញាប់**

# កម្ពុជា  :  សូមបិទមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនដោយបង្ខំ

*គោរពសិទ្ធិនិងបង្កើតការព្យាបាលដោយស្ម័គ្រចិត្តតាមមូលដ្ឋានសហគមន៍*

(ទីក្រុងបាងកក ថ្ងៃទី២៥ ខែមករា ២០១០) - អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានថ្លែងក្នុងរបាយការណ៍មួយដែលចេញផ្សាយនៅថ្ងៃនេះថា អ្នកប្រើប្រាស់គ្រឿងញៀននៅក្នុងប្រទេសកម្ពុជា កំពុងប្រឈមគ្រោះថ្នាក់នឹងការឃុំខ្លួនតាមអំពើចិត្តក្នុងមជ្ឈមណ្ឌល ជាទីកន្លែងដែលនោះពួកគេទទួលរងនូវទារុណកម្ម អំពើហិង្សាលើរាងកាយនិងផ្លូវភេទ និងទម្រង់ទណ្ឌកម្មឃោរឃៅផ្សេងៗទៀត។ មជ្ឈមណ្ឌលឃុំឃាំង ដែលមានសិទ្ធិអំណាចដើម្បីព្យាបាល និង"ស្តារនីតិសម្បទា" អ្នកប្រើប្រាស់គ្រឿងញៀន ក៏ប៉ុន្តែបែរជាធ្វើឱ្យពួកគេទទួលរងនូវការឆក់ចរន្តអគ្គិសនី ការវាយនឹងរំពាត់ខ្សែភ្លើង ពលកម្មដោយបង្ខំ និងហ្វឹកហ្វឺនយោធាដ៏យង់ឃ្នងទៅវិញ។

នៅក្នុងរបាយការណ៍៩៣ទំព័រ ដែលមានចំណងជើងថា "**ស្បែកដាច់ដាប់ខ្សែភ្លើង**" អង្គការឃ្លាំមើលសិទ្ធិមនុស្ស ធ្វើកំណត់ត្រាអំពីអ្នកជាប់ឃុំឃាំងដែលបានទទួលរងការវាយដំ ការរំលោភសេពសន្ថវៈ ការបង្ខិតបង្ខំឱ្យបរិច្ចាគឈាម និងទទួលរងនូវទណ្ឌកម្មលើរាងកាយដ៏ឈឺចាប់ ដូចជា"រមៀលធុងសាំង" (រមៀលខ្លួននៅលើដី) និងត្រូវគេដាក់ច្រវាក់ឱ្យឈរក្រោមកំដៅថ្ងៃ។ អង្គការឃ្លាំមើលសិទ្ធិមនុស្សក៏បានរាយការណ៍ផងដែរថា ចំនួនអ្នកជាប់ឃុំឃាំងយ៉ាងច្រើន បានប្រាប់អំពីការទទួលទានអាហារស្អុយរលួយ ឬមានសត្វល្អិត និងអំពីរោគសញ្ញាដែលស្របទៅនឹងកង្វះជីវជាតិអាហារ។

លោកយ៉ូសេព្វ អេម៉ុន ដែលជានាយកផ្នែកសុខភាពនិងសិទ្ធិមនុស្សនៃអង្គការឃ្លាំមើលសិទ្ធិមនុស្ស បានមានប្រសាសន៍ថា "បុគ្គលទាំងឡាយដែលស្ថិតនៅក្នុងមជ្ឈមណ្ឌលទាំងនេះ មិនត្រូវបានព្យាបាល ឬស្តារនីតិសម្បទាទេ។ ពួកគេកំពុងត្រូវជាប់ឃុំខ្លួនដោយខុសច្បាប់ និងទទួលទារុណកម្មជាញឹកញាប់។ មជ្ឈមណ្ឌលទាំងនេះ មិនចាំបាច់កែលំអ ឬធ្វើការផ្លាស់ប្តូរទេ។ មជ្ឈមណ្ឌលទាំងនេះ ចាំបាច់ត្រូវបិទចោល"។

យោងតាមរបាយការណ៍ ប្រជាពលរដ្ឋត្រូវបានគេចាប់ខ្លួនតាមអំពើចិត្តជាញឹកញាប់ ដោយគ្មានដីកា ឬមិនសមហេតុផលអ្វីឡើយ ដែលជានិច្ចជាកាលធ្វើតាមការស្នើពីសាច់ញាតិ ឬការឡោមព័ទ្ធចាប់តាមកាលកំណត់របស់នគរបាល មកលើប្រជាពលរដ្ឋដែលគេចាត់ទុកថាជា "ជនដែលសង្គមមិនរាប់អាន"។ ពួកគេត្រូវគេបាននិយាយកុហក ឬមិននិយាយប្រាប់ឱ្យដឹងអំពីហេតុផលចាប់ខ្លួនពួកគេទេ។ ពួកគេមិនទទួលបានមេធាវីការពារខ្លួន អំឡុងពេលស្ថិតក្រោមការឃុំឃាំងរបស់នគរបាល ឬអំឡុងពេលជាប់ឃុំឃាំងបន្ត នៅក្នុងមជ្ឈមណ្ឌលទេ។

ការហ្វឹកហ្វឺនយោធា ការបែកញើសក្នុងពេលហាត់ប្រាណ និងពលកម្ម គឺជាមធ្យោបាយជាទៀតទាត់បំផុត ត្រូវបានគេប្រើប្រាស់សម្រាប់ "ព្យាបាល" ពីការញៀនគ្រឿងញៀនក្នុងមជ្ឈមណ្ឌលទាំងនេះ ដែលកំពុងត្រូវបានអនុវត្តដោយអង្គភាពផ្សេងៗរបស់រដ្ឋាភិបាល រួមមានកងកម្លាំងនគរបាលស៊ីវិល និងកងរាជអាវុធហត្ថ។ សកម្មភាព "បណ្តុះបណ្តាលវិជ្ជាជីវៈ" ដែលកើតមាននៅក្នុងមជ្ឈមណ្ឌលមួយចំនួន ហាក់ដូចធ្វើសម្រាប់ផលចំណេញដល់បុគ្គលិកមជ្ឈមណ្ឌល ជាការប្រឆាំងនឹងអ្នកជាប់ឃុំឃាំង។ របាយការណ៍នេះ បានបំភ្លឺឱ្យឃើញចំនួនកុមារដ៏ច្រើន និងបុគ្គលដែលមានជំងឺផ្លូវចិត្ត ក៏ត្រូវជាប់ឃុំឃាំងនៅក្នុងមជ្ឈមណ្ឌលផងដែរ។ យោងតាមរបាយការណ៍ ប្រជាពលរដ្ឋទាំងពីរក្រុមនេះ ទទួលរងនូវការរំលោភលើរាងកាយដូចគ្នា។

អង្គការឃ្លាំមើលសិទ្ធិមនុស្ស សូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា ឱ្យបិទជាស្ថាពរនូវមជ្ឈមណ្ឌលឃុំឃាំងគ្រឿងញៀនរបស់ខ្លួន និងធ្វើការស៊ើបអង្កេតដោយល្អិតល្អន់ នូវអំពីទារុណកម្ម ការធ្វើទុក្ខបុកម្នេញ ការឃុំឃាំងតាមអំពើចិត្ត និងការរំលោភដទៃទៀតដែលកើតមាននៅក្នុងមជ្ឈមណ្ឌលទាំងនេះ។ ទារុណកម្ម និងប្រព្រឹត្តកម្មដ៏អមនុស្សធម៌ ត្រូវបានហាមឃាត់ដោយកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់រដ្ឋាភិបាល និងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា។

លោកអេម៉ុន បានមានប្រសាសន៍ដូច្នេះថា :- "រដ្ឋាភិបាលកម្ពុជា ត្រូវតែបញ្ឈប់ទារុណកម្ម ដែលកើតមាននៅក្នុងមជ្ឈមណ្ឌលទាំងនេះ។ ការញៀនគ្រឿងញៀន អាចដោះស្រាយបានតាមរយៈការព្យាបាលដោយ

ស្ម័គ្រចិត្ត នៅតាមមូលដ្ឋានសហគមន៍ នៅក្រៅមន្ទីរពេទ្យ ដែលគោរពសិទ្ធិមនុស្ស និងសមប្រទៅតាមបទដ្ឋានអន្តរជាតិ"

ការពិពណ៌នាដែលជ្រើសចេញពីអ្នកដែលបានសម្ភាសសម្រាប់របាយការណ៍ "**ស្បែកដាច់ជាប់ខ្សែភ្លើង**" :-

"ខ្ញុំគិតថា កន្លែងនេះមិនមែនជាមណ្ឌលស្តារនីតិសម្បទាទេ ប៉ុន្តែវាគឺជាមជ្ឈមណ្ឌលសម្រាប់ធ្វើទារុណកម្ម" - អតីតអ្នកជាប់ឃុំឃាំងម្នាក់ឈ្មោះកក្កដា បាននិយាយដូច្នេះ។

"[បុគ្គលិក] បានយកខ្សែអយវាយ... វាត់រហូតដល់ធ្វើឱ្យស្បែកដាច់ជាប់នឹងខ្សែភ្លើង..." —កុមារាឈ្មោះម្នាស់ អាយុ ១៦ឆ្នាំ បានពិពណ៌នាអំពីការវាត់នឹងខ្សែភ្លើង ដែលបានឃើញផ្ទាល់ភ្នែកនៅ "មណ្ឌលយុវនីតិសម្បទា" សង្គមកិច្ចចោមចៅ។

"[បន្ទាប់ពីចាប់ខ្លួន] ប៉ូលិសរុករកពេញខ្លួនរបស់ខ្ញុំ។ ពួកគេយកលុយខ្ញុំ និងដកហូតគ្រឿងញៀនរបស់ខ្ញុំទុក... ពួកគេនិយាយថា "បើអត់លុយ ទៅដើរលេងជាមួយខ្ញុំទៅ?... ពួកគេ [នគរបាល] បានដឹកខ្ញុំទៅផ្ទះសំណាក់មួយ... តើខ្ញុំត្រូវបដិសេធមិនព្រមដេកជាមួយគាត់ម្តេចកើត។ ខ្ញុំត្រូវតែធ្វើដូច្នេះ។ មានមេប៉ូលិសពីរនាក់ [ដែលខ្ញុំបានរួមភេទជាមួយ] ម្នាក់ម្តង១។ បន្ទាប់មកគេឱ្យខ្ញុំត្រឡប់ទៅផ្ទះវិញ "- មីនាជាស្ត្រីម្នាក់ស្ថិតក្នុងវ័យមធ្យម ២០ ឆ្នាំ និងជាអ្នកប្រើប្រាស់គ្រឿងញៀន បានពន្យល់ប្រាប់អំពីរបៀបនគរបាលពីរនាក់បានរំលោភផ្លូវភេទនាង។

"[បន្ទាប់ពីមកដល់ភ្លាម១] ខ្ញុំសន្លប់លែងដឹងខ្លួន។ អ្នកជាប់ឃុំឃាំងបានវាយខ្ញុំ... ពួកវាយកភួយមកគ្របលើខ្ញុំ ហើយវាយធ្វើបាបខ្ញុំ... ពួកវាវាយខ្ញុំចំកណ្តាលមុខ ដើមទ្រូង ចំហៀងខ្លួន។ ខ្ញុំមិនដឹងថាគេវាយអស់រយៈពេលប៉ុណ្ណាទេ... បុគ្គលិកបានបញ្ជាឱ្យអ្នកជាប់ឃុំជាមួយគ្នាវាយខ្ញុំ។ បុគ្គលិកបាននិយាយថា "មាន់ថ្មីមកដល់ហើយរើយ ដកស្លាបវាស៊ីទៅ!" - ដួងចែម អតីតអ្នកជាប់ឃុំឃាំង។